# កិច្ចសំភាសន៍របស់អ៊ំប្រុសឈ្មោះ អាន សំអាត

**កៈ អ្នកសំភាសន៍ឈ្មោះ ថូម៉ាស បារិត្ត** **ខៈ អ្នកដែលត្រូវសំភាសន៍ឈ្មោះសំអាត**

កៈ ជាដំបូងសូមគោរពជម្រាបសួរ អ៊ំប្រុស។

ខៈ បាទជម្រាបសួរ!

កៈ អរគុណដែលបានអនុញ្ញាតឲ្យពួកយើងមកដើម្បីសម្ភាសន៍អ៊ំប្រុស។ ហើយគោលបំណងរបស់ពួកយើងមកថ្ងៃនេះគឺរក្សាទុកនូវ ដូចជាបទពិសោធ និងសាច់រឿងទាំងឡាយរបស់អ៊ំប្រុស តាំងពីពេលកើតមកនៅកម្ពុជា រហូតមកដល់បច្ចុប្បន្ននេះ។ ហើយសម្រាប់ខ្ញុំផ្ទាល់ខ្ញុំបាទឈ្មោះ ថូម៉ាស បារិត្ត។ ខ្ញុំជាកូនសិស្សមួយនៅក្នុងសាកលវិទ្យាល័យឈ្មោះថា BYU ហើយឥឡូវខ្ញុំតំណាងសាកលវិទ្យាល័យមួយហ្នឹង នៅទីក្រុង Provo, Utah ។ អញ្ចឹងខ្ញុំនិង Dana Bourgerie និង Debra ពួកយើងជាអ្នកតំណាងឲ្យ កម្រងប្រវត្តិសាសន៍ផ្ទាល់មាត់នៃប្រជាជនខ្មែរ ហើយ BYU គេក៏កាន់គម្រោងមួយហ្នឹង។ អញ្ចឹងសម្រាប់ពួកយើង ដើម្បីចាប់ផ្តើម ខ្ញុំសុំសួរសំណួរសំខាន់មួយ។ ចង់សួរថា ក្រោយពីយើងធ្វើការថតសំឡេងការសម្ភាសមួយនេះ យើងចង់ដាក់ការសម្ភាសមួយហ្នឹងនៅក្នុងវេបសាយរបស់ពួកយើងនូវខាង BYU ។ យើងចង់សួរថាតើយើងមានការអនុញ្ញាតដើម្បីដាក់ការសម្ភាសមួយនេះនៅក្នុងវេបសាយយើងដែរឬទេ?

ខៈ បាទខ្ញុំអនុញ្ញាតិអោយធ្វើ។ បាទ។

កៈ អូខេ អគុណច្រើន។ អញ្ចឹងដើម្បីចាប់ផ្តើមការសម្ភាសមួយនេះ ខ្ញុំសុំសួរសំណួរសំខាន់បំផុត គឺ ឈ្មោះពិតប្រាកដរបស់អ៊ំប្រុស គឺជាអ្វី? ឈ្មោះពេញ?

ខៈ បាទ ខ្ញុំឈ្មោះ អាន សំអាត។ ត្រកូលខ្ញុំឈ្មោះ អាន  ខ្ញុំឈ្មោះ សំអាត។

កៈ ហើយត្រកូលមកពីខាងប៉ាឬក៏ខាងម៉ាក់?

ខៈ ត្រកូលខាងប៉ា។

កៈ ខាងប៉ា ល្អ។ អូខេ ល្អមែនទែន។ ចុះ ពេលធំឡើងមានឈ្មោះគេហៅក្រៅទេ?

ខ៖ មានហៅ សឹម ដែរ។

ក៖ សឹម? ចុះហេតុអ្វីគេហៅ សឹម?

ខ៖ ឈ្មោះហៅលេងម៉ង។

ក៖ ហៅលេង អូខេ ល្អ។ ទាំងពីក្មេងឬថ្មីៗនេះ?

ខ៖ ទាំងពីក្មេង។

ក៖ ទាំងពីក្មេងឯ

ខ៖ បាទ។

ក៖ ហើយសព្វថ្ងៃនេះ អ៊ំប្រុសមានអាយុប៉ុន្មាន?

ខ៖ ៧២ឆ្នាំ។

ក៖ អូខេ ៧២ឆ្នាំ។ ហើយកើតនៅឆ្នាំណាដែរ?

ខ៖ កើតនៅខែប្រាំបួន ថ្ងៃទីដប់ប្រាំបី។ ថ្ងៃស្អែកហ្នឹងហើយ។

ក៖ ថ្ងៃស្អែក អូចុំ!

ខ៖ ឆ្នាំ១៩៥២។

ក៖ អូខេ ចាំច្បាស់ ល្អ។ ហើយអ៊ំប្រុសបានកើតនៅកន្លែងណាដែរ? នៅកម្ពុជា?

ខ៖ ប្រភពដើមខ្ញុំចេញមកពីប្រទេសខ្មែរ គេហៅថាប្រទេសកម្ពុជា។ ស្រុកកំណើតខ្ញុំ ភូមិគោកមន សង្កាត់គោកមន ស្រុកអំពិល ខេត្តឧត្តរមានជ័យ។

ក៖ អូ ឧត្តរមានជ័យ! ដូចនៅខាងជើង។

ខ៖ នៅខាងជើង។ ជិតព្រំប្រទល់ថៃ។

ក៖ ចុះ តើឪពុកម្ដាយ គេមកពីឧត្តរមានជ័យដែរ ឬក៏—?

ខ៖ បាទ ឪពុកម្ដាយខ្ញុំគាត់កើតនៅហ្នឹង គាត់ធំនៅហ្នឹង រស់នៅ រៀបការនៅហ្នឹង ស្លាប់នៅកន្លែងហ្នឹងដែរ។

ក៖ អូខេ។

ខ៖ បាទ។

ក៖ ល្អ។ ហើយ អ៊ំប្រុសចេះភាសាខ្មែរហើយ ខ្ញុំឮថាអ៊ំប្រុសចេះអង់គ្លេសខ្លះដែរ។

ខ៖ បាទ ខ្ញុំចេះភាសាអង់គ្លេសខ្លះៗ ចេះភាសាខ្មែរ ភាសាថៃ ភាសាឡាវ។

ក៖ ភាសាឡាវ អូខេ អញ្ជឹងចំនួនបួន?

ខ៖ បាទបួន។ ហើយចង់ភ្លិចខ្លះ អត់ដែលបាននិយាយយូរ។

ក៖ អូខេ អត់អីទេ។ អញ្ជឹងចង់សួរថា ខាងភាសាខ្មែរ ចេះសរសេរ ចេះអានទេ?

ខ៖ បាទ។

ក៖ ចេះច្បាស់។

ខ៖ បាទៗ។

ក៖ ចុះអង់គ្លេស? ចេះអាន ឬក៏អត់ទេ?

ខ៖ អង់គ្លេសចេះអាន ចេះសរសេរបាន បន្ទិចបន្ទួតដែរ។

ក៖ អូខេ ល្អ ឆ្លាតអញ្ជឹង។ អូខេ ខ្ញុំប្រហែលជាប្ដូរប្រធានបទទៅប្រវត្តិនៃក្រុមគ្រួសារ អញ្ជឹងចង់សួរថា ឪពុកម្ដាយ គេកើតនៅឧត្ដរមានជ័យ អ៊ំស្គាល់ភូមិឃុំទេ?

ខ៖ កើតនៅឧត្ដរមានជ័យ ភូមិគោកមន សង្កាត់គោកមន ស្រុកអំពិល ខេត្តឧត្ដរមានជ័យ។

ក៖ ស្រុកដដែល?

ខ៖ ស្រុកដដែល។

ក៖ អូខេ ល្អ។ ហើយចុះឪពុកម្ដាយមានឈ្មោះអ្វី?

ខ៖ ឪពុកខ្ញុំឈ្មោះ អាន។ អាន ប៉ុន្តែគាត់យកឈ្មោះឪពុកគាត់ធ្វើជាត្រកូលឈ្មោះ ព្រឹម។

ក៖ ព្រឹម?

ខ៖ បាទ ព្រឹម អាន។

ក៖ ព្រឹម អាន។

ខ៖ បាទ។ ម្ដាយឈ្មោះ ហាន នាមត្រកូលគាត់ឈ្មោះ សាត ។

ក៖ សាត។

ខ៖ បាទ។

ក៖ ចុះបើប្រកប យើងប្រកបយ៉ាងម៉េច? ឈ្មោះម៉ែ?

ខ៖ ឈ្មោះ— ?

ក៖ Uh huh, បើ spell បើប្រកប?

ខ៖ អូ ប្រកប ជាភាសាអង់គ្លេសឬក៏ភាសាខ្មែរ?

ក៖ ខ្មែរ។

ខ៖ អូខ្មែរ សាត ហាន។

ក៖ អូខេ ចុះ អ៊ុំប្រុសដឹងថាគេកើតនៅឆ្នាំណាទេ?

ខ៖ ខ្ញុំអត់ដឹង។

ក៖ អត់ដឹង?

ខ៖ អត់ដឹង ចាំអត់បាន។

ក៖ អត់ចាំ។

ខ៖ គាត់មិនបាននិយាយប្រាប់ផង។ ជាពិសេសជំនាន់ហ្នឹង កម្រអត់បានដឹង ថ្ងៃខែកំណើតខ្លួនកើត ព្រោះអីស្រុកខ្ញុំនៅហ្នឹងស្រុកជនបទដាច់ស្រយាល។ មិនមាននៅជិតទីក្រុងទេ។

ក៖ ចុះអ៊ុំស្គាល់ឆ្នាំខ្មែរគេ ដូចជា ឆ្នាំឆ្លូវ ឆ្នាំថោះឬក៏អ៊ុំស្គាល់?

ខ៖  មានគាត់ស្គាល់ដែរ ប៉ុន្តែអឺ— ខ្ញុំដូចមិន— គាត់ធ្លាប់និយាយប្រាប់ខ្ញុំដែរ ប៉ុន្តែខ្ញុំចាំមិនបាន។

ក៖ ចាំមិនបាន?

ខ៖ បាទ។

ក៖  អូខេ អត់អីទេ ប្រហែលយូរហើយ។ អូខេ ហើយអ៊ំប្រុសធ្លាប់និយាយថា គេស្លាប់នៅឧត្តរមានជ័យដូចគ្នាដែរមែន?

ខ៖ បាទ។ ឪពុកខ្ញុំស្លាប់មុន។ ពីរឆ្នាំម្តាយខ្ញុំស្លាប់តាមក្រោយ។

ក៖ អូខេ យល់។ ចុះអ៊ំប្រុសចាំឆ្នាំដែលឪពុករបស់អ៊ុំប្រុសបានស្លាប់?

ខ៖ ឆ្នាំ! អូឪពុកខ្ញុំស្លាប់ប្រហែលជា ខ្ញុំចាំអត់បានទេ ប្រហែលជាឆ្នាំ ១៩៦៨ - ៦៩ ហ្នឹងឯង។

ក៖ អូខេ មុនប៉ុលពតអញ្ចឹង។

ខ៖ បាទ មុនប៉ុលពតមួយឆ្នាំ ពីរឆ្នាំហ្នឹង ប្រហែលខ្ទង់ហ្នឹង។

ក៖ អូខេយល់។ ល្អ ហើយសម្រាប់គេ គេកូនខ្មែរឬក៏គេកាត់?

ខ៖ គាត់ជាកូនខ្មែរ។

ក៖ កូនខ្មែរទាំងពីរ?

ខ៖ ខ្មែរទាំងពីរនាក់ ។

ក៖ អូខេ ល្អ។ អញ្ចឹងអ៊ំប្រុសខ្មែរសុទ្ធ។

ខ៖ បាទ។

ក៖ ខ្មែរសុទ្ធ ល្អ។ ចុះ អ៊ំប្រុសមានបងប្អូនទេ ?

ខ៖ បាទ។ ឪពុកម្ដាយខ្ញុំ គាត់មានកូនប្រាំមួយ— ប្រាំពីរនាក់។ ប្រុសបីនាក់ ស្រីពីរនាក់។ [គាត់ភ្លេចរាប់កូនទី៦ជាស្រី]

ក៖ អូខេ ប្រាំពីរនាក់រួមទាំងអ៊ំប្រុស?

ខ៖ បាទ។ ប្រាំពីរនាក់ទាំងខ្ញុំ។

ក៖ អូខេ ចុះចាំឈ្មោះរបស់ពួកគេទាំងប្រាំពីរនាក់ទេ?

ខ៖ កូនច្បងទីមួយឈ្មោះ អាន សឿន ។ ឥឡូវហ្នឹងគាត់នៅ Paris, France ។

ក៖ គាត់នៅ Paris? គាត់ប្រុសឬក៏ស្រី?

ខ៖ កូនប្រុស។ ហើយបន្ទាប់ពីហ្នឹងមួយទៀតមាន អាន សាគាល ។

ក៖ អាន សាគាល ។

ខ៖ គាត់នៅ Iowa State។

ក៖ គាត់នៅ Iowa គាត់ប្រុសឬស្រី?

ខ៖ ស្រី។ ហើយបន្ទាប់មកទៀតមាន អាន សោត ។

ក៖ អាន សោត។

ខ៖ ប្រុស។ គាត់ស្លាប់បានប្រាំឆ្នាំហើយ នៅតាកូម៉ាហ្នឹង។

ក៖ នៅតាកូម៉ា។

ខ៖ បាទ។ ហើយបន្ទាប់ពីបងសោតមក ខ្ញុំផ្ទាល់។

ក៖ អូ អូខេ ទីបួនអញ្ចឹង។

ខ៖ បាទ ទីបួន។ ហើយបន្ទាប់ពីខ្ញុំមានប្អូនស្រីមួយទៀតឈ្មោះ អាន ហួន ។

ក៖ អាន ហួន ។

ខ៖ ប៉ុនគេហៅថា អាន គឹមហួន។

ក៖ អាន គឹមហួន ។

ខ៖ បាទ គាត់ជាស្រី។ គាត់សព្វថ្ងៃគាត់រស់នៅ Montreal, Quebec ។

ក៖ អូមែន? នៅ Canada ។

ខ៖ បាទនៅ Canada ។ [គាត់មានប្អូនស្រីមួយទៀត ប្អូនទី៦ឈ្មោះ អាន គឹមហៀន] ហើយកូនពៅគេ [ប្អូនប្រុស] ឈ្មោះ អាន ពិសិដ្ឋ គាត់ស្លាប់បាត់ហើយ ស្លាប់នៅក្នុងឆ្នាំ ១៩៧៧។

ក៖ '៧៧ អូខេ។ គាត់ស្លាប់នៅណា? នៅខ្មែរ?

ខ៖ នៅខ្មែរ។ ខ្មែរក្រហមយកគាត់ទៅសម្លាប់ចោល។

ក៖ អូខេយល់ច្បាស់។

ខ៖ បាទ។

ក៖ អូខេយល់។ ចុះចង់សួរថាអំពើមានអនុស្សាវរីយ៍ជាមួយនឹងបងប្អូនឬក៏ជាមួយឪពុកម្តាយនៅខ្មែរទេ?

ខ៖ ខ្ញុំមានអនុស្សាវរីយ៍ច្រើនណាស់។ ជាពិសេសខ្ញុំរស់នៅភាពជនបទ— ព្រៃភ្នំ ស្រែចំការ រកស៊ីតាមធម្មជាតិធម្មតា សប្បាយមួយជំនាន់ហ្នឹងសប្បាយ សម្បូរសត្វ សម្បូរផ្លែឈើ សម្បូរអីគ្រប់យ៉ាង។ ទោះបីជាមិនមានម៉ាស៊ីនក៏យើងអាចរស់បាន កន្លែងហ្នឹងក៏អត់មានបញ្ហាអី រស់ស្រួលមែនទែន។ ហើយអនុស្សាវរីយ៍ឪពុកម្តាយខ្ញុំ គាត់ធ្វើការជាធម្មតាជាអ្នកស្រែ។ ហើយខ្ញុំក្មេងៗ— អនុស្សាវរីយ៍ច្រើនជាមួយគាត់។ ដល់ពេលខ្ញុំធំហ្នឹងខ្ញុំ ចងក្រងក្នុងខួរក្បាលខ្ញុំជានិច្ច អនុស្សាវរីយ៍ដែលគាត់បង្រៀនខ្ញុំបាន មកឲ្យខ្ញុំបានធ្វើបានល្អជាមនុស្សមួយដែលមានចិត្តធម៌ដូចជាគាត់ដែរ។

ក៖ ល្អ រៀនតាមគ្រួសារ សប្បាយ។ ហើយអ៊ំមានអនុស្សាវរីយ៍ដូច— ខ្ញុំឮថា នៅក្នុងភូមិនីមួយៗ មានអ្នកខ្លះគេមានចេះត្បាញឬក៏ចេះឡើងត្នោត ឬក៏គេមានជំនាញអីផ្សេង។ ចង់សួរថាអ៊ំធ្លាប់រៀនជំនាញពីក្រុមគ្រួសារទេ?

ខ៖ អត់មានផង។ មានតែខាងស្រែ ធ្វើស្រែធ្វើចំការ។

ក៖ ធ្វើស្រែចំការ។

ខ៖ ហើយនិងប្រមាញ់សត្វ ហើយនិងស្ទូចត្រី តែប៉ុណ្ណឹងឯង។ អត់មានអីផង។

ក៖ អូខេ អញ្ចឹងធ្វើ— មានជីវិតស្រែចំការ។

ខ៖ បាទ។

ក៖ អូខេ សប្បាយ។ ហើយភាគច្រើន ប៉ាជាអ្នកធ្វើស្រែចំការ ចុះម៉ែជួយគាត់ ឬក៏ម្ដាយរបស់អ៊ំប្រុសធ្វើការនៅផ្ទះ។

ខ៖ អឺ ជួយគ្នាទៅវិញទៅមក។ តាមកិច្ចការដែលត្រូវការជួយ។ ជួនកាលឪពុកខ្ញុំជួយខាងម្ដាយ ជួនកាលម្ដាយខ្ញុំជួយកិច្ចការខាងឪពុក។ ជួយគ្នាទៅវិញទៅមក។

ក៖ ល្អណាស់។ អូខេ ចង់សួរអំពីលោកតាលោកយាយរបស់អ៊ំប្រុស ខាងម៉ែខាងឪ។ ចង់សួរថា គេមានឈ្មោះអ្វី? ចាំគាត់? ធ្លាប់ជួបជាមួយគាត់ទេ?

ខ៖ បើយាយខ្ញុំ ខ្ញុំជួប។ តាខ្ញុំអត់បានជួបអី។ ប៉ុន្តែខ្ញុំចាំឈ្មោះគាត់ភាគច្រើនម៉ង។ ហើយខ្ញុំក៏បានធ្វើជាប្រវត្តិគ្រួសារ នៅក្នុងវេបសាយដែរ។

ក៖ នៅក្នុងវេបសាយ FamilySearch មែន? ឬក៏ខាងណា?

ខ៖ នៅក្នុងវេបសាយខាងសាសនាចក្រ។

ក៖ ហើយឈ្មោះរបស់ពួកគេគឺជាអ្វី?

ខ៖ ឈ្មោះឪពុកខាង— យាយតាខ្ញុំឈ្មោះ តា ព្រឹម។ ប៉ុន្តែខ្ញុំអត់ដឹងឪពុក តាព្រឹមទេ។ អត់ដឹងទេ ខ្ញុំចាំអត់បានទេ។ ប៉ុន្តែយាយខ្ញុំឈ្មោះ យាយ ម៉ាន់ ។ គាត់ជាឪពុកម្ដាយឪពុករបស់ខ្ញុំ។ យើងហៅតែ តាព្រឹម យាយម៉ាន់។ តែប៉ុណ្ណឹងអី អត់មានដឹងឈ្មោះអី នាមត្រកូលគាត់ប៉ុន្មានអី ខ្ញុំអត់ដឹងផងហ្នឹង មួយជំនាន់ហ្នឹង។ ហើយខាងម្ដាយខ្ញុំ ឈ្មោះ តា សាត ជាឪពុករបស់ម្ដាយខ្ញុំ។ ហើយប្រពន្ធគាត់ឈ្មោះ— អឺ— យាយ នេម! ខ្ញុំភ្លេចដែរ។ យាយនេម។

ក៖ អូខេ ហើយអ៊ំដឹងថា គេកើតនៅក្នុងឆ្នាំណាឬក៏អត់?

ខ៖ អូ!!

ក៖ អត់ដឹង? ប្រហែលយូរហើយ។

ខ៖ ខ្ញុំចាំមិនបាន មួយជំនាន់ហ្នឹង។ ចាំអត់បានទេ ព្រោះអី គាត់អត់ដែលប្រាប់យើងផង។ ជំនាន់ហ្នឹងមិនដែលប្រាប់ទេ។ គាត់កើតឆ្នាំកំណើតខែណាឪពុកម្ដាយគាត់មិនដែលប្រាប់កូនដែរ។

ក៖ អូខេ ខ្ញុំយល់ច្បាស់ គ្រាន់តែចង់សួរអញ្ចឹង។ អូខេល្អ ហើយចង់សួរសំណួរពាក់ព័ន្ធទៅនឹងការរៀបការ។ ចង់សួរ អ៊ំប្រុសបានរៀបការមែនទេ? ហើយរៀបការជាមួយអ្នកណាគេ? ហើយគាត់ឈ្មោះអ្វីដែរ?

ខ៖ បាទដំបូង ខ្ញុំរៀបការកូនខ្មែរម្នាក់នៅស្រុកភូមិដាច់ស្រយាលពីផ្ទះខ្ញុំដែរ ប៉ុន្តែនៅខេត្តជាមួយគ្នា។ បាទ ប៉ុន្តែឥឡូវហ្នឹងគាត់ស្លាប់បាត់ហើយ។ បានកូនមួយជាមួយគ្នាតែប៉ុណ្ណឹងឯង។

ក៖ អូ អូខេ គាត់ឈ្មោះអ្វី?

ខ៖ គាត់ឈ្មោះ ព្រេម សូជឿត។

ក៖ ហើយគាត់ស្លាប់នៅឆ្នាំណាដែរ?

ខ៖ ក៏ស្លាប់បានប្រហែលជាបួនឆ្នាំប្រាំ ឆ្នាំហើយ បាទ។

ក៖ អូខេ ហើយមានប្រពន្ធតែមួយ ឬក៏— ?

ខ៖ បាទខ្ញុំបែកបាក់ពីគាត់ជំនាន់ខ្មែរក្រហម មុនដំបូង។ បាទ។ ដល់ពីរឆ្នាំចិតសិប [១៩៧២] ហ្នឹងពេលស្រុកខ្មែរមានសង្គ្រាមឡើង កើតឡើងមកហ្នឹងក៏ ខ្ញុំដាច់ចិត្តឈប់រៀន។ ខ្ញុំបានចូលរៀន college ប៉ុន្តែមិនបានមួយឆ្នាំផងហ្នឹង។ មិនបានមួយឆ្នាំហ្នឹង ក៏គេត្រូវការរើសទាហានដើម្បីជួយការពារជាតិយើង។ ខ្ញុំទៅចូលទៅធ្វើទាហានពេលហ្នឹងទៅ។

ក៖ ធ្វើទាហានខាងលន់នល់?

ខ៖ ទាហានខាងលន់នល់។

ក៖ លន់នល់ អូខេ។ ហើយអ៊ំបានជាប់បាក់ឌុបហើយមែន?

ខ៖ បាទ?

ក៖ ជាប់បាក់ឌុបហើយមែន? ថ្នាក់ទី១២?

ខ៖ បាទ ចប់។ ចប់ហើយខ្ញុំបានចូល college បានពាក់កណ្តាលឆ្នាំដែរ។

ក៖ អូ អូខេ យល់។ ចុះធ្វើទាហានខាងលន់នល់បានប៉ុន្មានឆ្នាំ?

ខ៖ បានប្រាំឆ្នាំ។ ១៩៧០ ដល់ ១៩៧៥។

ក៖ បានប៉ុលពតចូល។

ខ៖ ប៉ុលពតចូលវាយយើង ខ្ញុំបានឈប់ទៅកន្លែងហ្នឹង។

ក៖ អូខេ ហើយធ្វើទាហាននៅណាដែរ?

ខ៖ ធ្វើទាហាននៅខេត្តឧត្តរមានជ័យដដែល។

ក៖ ឧត្តរមានជ័យ។

ខ៖ បាទ។

ក៖ ហើយចូលប៉ុលពត— ចង់សួរខ្លះៗអំពីប៉ុលពត ដោយសារតែយើងបាននិយាយអំពីប្រធានបទមួយហ្នឹងហើយ។ ចង់សួរថា ចូលឆ្នាំ '៧៥ នៅឧត្តរមានជ័យដដែលមែន?

ខ៖ បាទៗ។

ក៖ អូខេ ហើយគេជម្លៀសអ៊ំប្រុសទៅកន្លែងណាផ្សេងឬក៏នៅឧត្តរមានជ័យដដែល?

ខ៖ ពីដើមឡើយ នៅពេលយើងចាញ់សង្គ្រាមជាមួយខ្មែរកុម្មុនិស ខ្ញុំក៏បោះអាវុធខ្ញុំគ្រាប់រំសេវផ្លាស់ខោអាវ ទុកក្នុងទឹកស្ទឹងមួយ។ បោះចោលហើយស្លៀកពាក់ខោអាវស៊ីវិល ដើរដើម្បីបន្លំខ្លួនជាមួយជនជាតិស៊ីវិលធម្មតាហ្នឹង។ ខ្ញុំក៏ដើរតម្រង់ទៅស្រុកភូមិខ្ញុំវិញ។

ក៖ អត់ចង់ឲ្យគេដឹងថាយើងគឺជាទាហាន?

ខ៖ អត់ឲ្យគេដឹង។

កៈ អូខេយល់ច្បាស់។ ហើយទៅភូមិណា?

ខៈ បាទ ខ្ញុំចូលទៅស្រុកភូមិកំណើតខ្ញុំម៉ង។

កៈ អូខេ ហើយចូលជំនាន់ប៉ុលពត អ៊ំមានអាយុប៉ុន្មានឆ្នាំដែរ?

ខៈ ខ្ញុំចាំមិនបានប្រហែលជា ម្ភៃប្រាំ ម្ភៃប្រាំមួយអីហ្នឹង។ ប្រហែល។

កៈ ម្ភៃប៉ុន្មាន។

ខៈ ម្ភៃប្រាំ ម្ភៃប្រាំមួយ ខ្ទង់ហ្នឹងឯង។

កៈ អូខេ ប្រហែលជាយើងត្រឡប់ទៅវិញអំពីខ្មែរក្រហម— អំពីបទពិសោធដែលអ៊ំប្រុសបាន ឆ្លងកាត់នៅក្នុងសម័យប៉ុលពត។

ខៈ អូខេ កាលដើមឡើយ ខ្ញុំជាសិស្សសាលា។ នៅពេលឆ្នាំ ១៩៧០ ខ្ញុំក៏ចូលទៅធ្វើទាហាន ធ្វើទាហានបានប្រាំឆ្នាំ។ ហើយខ្ញុំមិនបាច់ប្រាប់ការរស់នៅរបស់ខ្ញុំ— កំពុងធ្វើទាហានម៉ែនទេ? មិនបាច់ប្រាប់ទេ ឬក៏ចង់ខ្ញុំនិយាយដែរ?

កៈ និយាយអ្វីក៏បាន។ បើចង់និយាយល្អ។

ខៈ បាទ។ ការធ្វើទាហានហ្នឹង វាពិបាកខ្លាំងណាស់មួយចំនាន់ហ្នឹង។ ចាំយើងបានជំនួយពីសហរដ្ឋអាមេរិកដែរគ្រឿងអាវុធហើយអីហ្នឹង។ ពួកខ្ញុំខាងសេរីខាងទទួលជំនួយពីអាមេរិចកាំងយើងដែរ។ ហើយក្នុងរវាងប្រាំឆ្នាំហ្នឹង ខ្ញុំមានមិត្តភក្តិច្រើនដែលធ្វើទាហាន ស្លាប់រាល់ថ្ងៃ មានថ្មីរាល់ថ្ងៃ។ ដោយសារមនុស្សស្លាប់រៀងរាល់ថ្ងៃ ទាហានហ្នឹង ប៉ុន្តែយើងមានទាហានមកចូលថ្មីបន្តៗជារៀងរាល់ថ្ងៃដែរ។ ម្ល៉េះហើយ ម្នាក់ៗនៅពេលហ្នឹងយល់ថា ថ្ងៃនេះយើងរស់ ថ្ងៃស្អែកយើងនឹងស្លាប់។ មនុស្សស្លាប់រាល់ថ្ងៃមិនដឹងអ្នកណាណាស្លាប់ទេ។ បាទសម្រេចចិត្តអញ្ចឹង។ យើងម្នាក់ៗភ្ញាក់ឡើងឃើញថ្ងៃរះឡើងថា ខ្ញុំនៅរស់។ I survived! ជារៀងរាល់ថ្ងៃ ចិត្តអញ្ចឹង ថាថ្ងៃស្អែកយើងនឹងស្លាប់ តែប៉ុណ្ណឹងឯង។ រហូតស្លាប់ច្រើនណាស់។ មានស្លាប់គ្រប់បែបយ៉ាងនៅពេលធ្វើសង្គ្រាមហ្នឹង មានភាពលំបាកខ្លាំងណាស់។ ប្រទេសខ្មែរ— ដល់ពេលដើមឆ្នាំ ‘៧៥ ហ្នឹង ១៩៧៥ កុម្មុយនីស្តគេបានវាយសម្រុកចូលខ្លាំងពេកទៅ ក៏យើងបានចាញ់គេ។ ពេលហ្នឹងឯងដែលខ្ញុំបានបន្លំខ្លួនឯងឲ្យធ្វើជាអ្នកស៊ីវិលហ្នឹង ចូលទៅក្នុង— ដើរជាមួយអ្នកស៊ីវិលដើរតាមផ្លូវដើម្បីបន្លំខ្លួនចូលទៅស្រុកភូមិខ្លួនឯងកំណើតដែរហ្នឹង។ ប៉ុន្តែដល់ភូមិកំណើត ខ្ញុំរស់

នៅបានធ្វើជាមួយខ្មែរក្រហមបានពីរឆ្នាំដល់ ១៩៧៧។ នៅពេលដែលខ្ញុំរស់នៅហ្នឹង ឃើញមនុស្សស្លាប់ច្រើនណាស់។ អត់អាហារ ហើយជាពិសេសយកទៅសម្លាប់ចោលម៉ង។ មានភូមិមួយជិតខ្ញុំឈ្មោះ ភូមិកំពុងទឹក។

កៈ  កំពុងទឹក។

ខៈ ភូមិកំពុងទឹក។ អាហ្នឹងមួយភូមិហ្នឹង ដឹកយកទាំងអស់ហ្នឹងទៅ សម្លាប់អស់មួយភូមិម៉ង។ ក្មេងៗគេយកទៅដាក់ផ្សេង មនុស្សចាស់យកទៅដាក់ផ្សេង មនុស្សស្រីដាក់ផ្សេង ហើយវាសម្លាប់អស់មួយភូមិម៉ង មួយភូមិហ្នឹងស្លាប់អស់លីង ភូមិកំពុងទឹកហ្នឹង។ បាទ ហើយវាកុហកថាវាជម្លៀសពីកន្លែងហ្នឹង ដើម្បីទៅផលិតផលនៅកន្លែងផ្សេងទៀតណាស់។ ទៅវាយកទៅសម្លាប់ចោលអស់ម៉ង អត់មានសល់ម៉ង។ បាទ ហើយខ្ញុំមានភាពរៀនសូត្រច្រើនកាលហ្នឹង ព្រោះអីខ្ញុំធ្លាប់ធ្វើទាហាន ធ្វើជាមេបញ្ជាការដែរ នៅពេលហ្នឹង។ កាន់ទាហានជាង ១០០ នាក់ដែរនៅពេលហ្នឹង។ ខ្ញុំមិនហ៊ានប្រាប់គេថា ខ្ញុំជានាយទាហាន ឬជាទាហាន ឬជាគ្រូបង្រៀន អ្នកដែលធ្វើការជាមួយកិច្ចការសម្រាប់រដ្ឋការ ខ្ញុំអត់ហ៊ានប្រាប់ទេ។ ព្រោះអីខ្ញុំឃើញគេយកទៅសម្លាប់ចោលណាស់ បើយើងនិយាយប្រាប់តាមត្រង់ហ្នឹងហើយ។ ម្ល៉េះហើយខ្ញុំលាក់ខ្លួនបំពួនអាត្មាដើម្បីជីវិត។ បាទ ហើយខ្ញុំពេលហ្នឹង គេសួរថាអ្នកឯងចេះអក្សរទេ? ថាខ្ញុំអត់ចេះទេ។ អ្នកចេះសរសេរ? ក៏អត់ចេះសរសេរទេ។ ខ្ញុំធ្វើដូចជាមនុស្សវិកលចរិត—uh, retarded ដើម្បីឲ្យគេយល់ថាយើងល្ងង់ខ្លៅ អត់មានគិតអីអាក្រក់ក្បត់វាថ្ងៃក្រោយទៀតទេ ប្រឆាំងវាថ្ងៃក្រោយទៀតទេ។ ប៉ុន្តែខ្ញុំធ្វើខោអាវខ្ញុំហែក ហើយខ្ញុំដេរម្តងទៀត។ យើងធ្វើដូចជាយើងល្ងង់ មិនដឹងសោះម៉ង មិនចេះសរសេរមិនចេះអីទាំងអស់ហ្នឹង មិនចេះអានទាំងអស់ហ្នឹង។ ប៉ុន្តែពេលណាខ្ញុំធ្វើហ្នឹងធ្វើតែរូបរាងកាយទេ ប៉ុន្តែក្នុងខួរក្បាលខ្ញុំសម្លឹងមើលវា។ សម្លឹងមើលវាទៅ អាហ្នឹងវាចូលចិត្តធ្វើអី ការសិក្សាអំពីវាហ្នឹង វាចំណុចខ្សោយវាអ្វីគេខ្លះ ចឹងនៅពេលណាខ្ញុំត្រូវគេយកទៅសម្លាប់ ខ្ញុំត្រូវធ្វើម៉េចដើម្បីដោះខ្លួនចេញពីកន្លែងវា។ ខ្ញុំរៀនសិក្សាទាំងអស់ រៀនសូត្រទាំងអស់។

កៈ រៀនសូត្រតាមគេ។

ខៈ បាទរៀនមើល។ ប៉ុន្តែអាគាំងថា you act stupid, you act retarded, but you watch them and study them, yeah. And then, you know, to get away from them to kill you. ហ្នឹងហើយ ពីរឆ្នាំហ្នឹង ជួបប្រទះច្រើន មានអ្នកដែលគេយកទៅសម្លាប់ដោយចងគ្នាពីក្រោយ ដើរក្រោយផ្ទះខ្ញុំមួយជួរអញ្ចឹងណាស? ចងយកទៅវាយសម្លាប់ចោលហ្នឹង។ ហើយចបខ្ញុំនៅលើរទេះនៅ

ក្រោយហ្នឹង វាយកទៅជាមួយដែរ។ វាយកទៅជាមួយដែរ ទៅវាយសម្លាប់គ្នាចោលអស់ទៅ ហើយយកចបដាក់ទុកខ្ញុំវិញ។ ព្រឹកឡើងឃើញឈាមមនុស្សលើចប សុទ្ធតែឈាម។ ហើយពេលយប់ៗជាមួយប្ដីប្រពន្ធអត់ហ៊ាននិយាយអីទេ។ អត់ហ៊ាននិយាយទេ ពួកវាយប់ឡើងក៏ពួកវានៅខាងក្រោមផ្ទះ វាចាំលបចាំស្ដាប់យើងនិយាយអ្វីៗអាក្រក់ទៅ វាចាប់យើង។ ម្ល៉េះហើយទៅ ពេលដែលយើងព្រឹកឡើងយើងមើលក្រោមផ្ទះ គឺសុទ្ធតែគន្លងវា (ស្នាមជើង) មនុស្សចាំក្រោមផ្ទះយើងហ្នឹង។ ម្ល៉េះហើយទៅយើងដឹងម៉ង យើងដឹងម៉ង។ ម្ល៉េះហើយហ្នឹង ការរស់នៅជាមួយខ្មែរក្រហមមានភាពពិបាក ឋាននរកម៉ង។ គ្មានធម៌គ្មានសាសនាអត់មានជំនឿអញ្ចឹងទេ។ កូនវាអប់រំឲ្យសម្លាប់ឪពុកម្ដាយ ពួកវាស្រឡាញ់ក្មេងៗតូចៗ ធំពេកវាអត់ស្រឡាញ់ វាយកដើម្បីយកទៅអប់រំ។ អប់រំ ដូចដឹងស្រាប់ហើយក្មេងដូចជាក្រដាសសអញ្ចឹង វាយកទៅលាបពណ៌អីក៏បានដែរ។  ម្ល៉េះហើយទៅ វាមានលាបពណ៌ក្រហមហើយវាឲ្យសម្លាប់ម្ដាយខ្លួនឯងក៏មានដែរ។ ម្ល៉េះហើយវា— ពេលហ្នឹងអត់មានទុកចិត្ត ប្រពន្ធអត់ទុកចិត្តប្ដី ប្ដីអត់ទុកចិត្តប្រពន្ធ កូនម៉ែឪទាំងអស់ហ្នឹង ពេលហ្នឹងដូចថាខ្លាចចិត្តគ្នាម៉ង ខ្លាចម៉ង អត់ហ៊ាននិយាយអាក្រក់ មិនហ៊ាននិយាយអីទេ ពិបាកៗពេលហ្នឹងវាមានភាពពិបាក។ ថ្ងៃមួយក្នុងឆ្នាំ '៧៧ ខ្ញុំទៅស្ទូងស្រែ ហើយឃើញខ្មែរក្រហមពីរនាក់ដើរមកតម្រង់ខ្ញុំ ហើយវាសួរថាចង់ឲ្យខ្ញុំយកខ្ញុំទៅជួយជួសជុលផ្ទះនៅក្នុងភូមិមួយដែលយប់មិញខ្យល់ព្យុះខ្លាំងពេក ឲ្យទៅជួសជុល។ ខ្ញុំក៏នឹកស្មានថា ម៉េចបានត្រូវការខ្ញុំតែមួយ ម៉េចមិនត្រូវការពីរនាក់? ខ្ញុំទៅមួយហើយ វាប្រាប់ទៀតថា មិនឲ្យទៅម្នាក់ឯងទេ ដើរជាមួយគ្នាវាដើម្បីនិយាយសប្បាយលេងតាមផ្លូវ។ ហើយខ្ញុំក៏ដឹងម្នាក់ឯង ខ្ញុំដឹងម៉ង។ ដឹងរបៀបគេចាប់មនុស្ស គេធ្វើអញ្ចឹងម៉ង។

ក៖ អូ!

ខ៖ បាទ ពេលហ្នឹងខ្ញុំក៏ថា «អូខេ» អញ្ចឹងក៏ប្រាប់វាថា «ខ្ញុំសូមទៅយកអីវ៉ែអីវ៉ាន់ខ្ញុំនៅផ្ទះ» ចុងព្រៃ នៅផ្ទះ។ ខ្ញុំនិយាយ អត់មានតក់ស្លុត និយាយធម្មតាមិនឲ្យពួកវាចាប់បាន។ ម្ល៉េះហើយទៅវាឲ្យទៅយកទៅ វាថា «ហ្នឹងហើយទៅយកទៅ ប៉ុន្តែត្រឡប់មកវិញចាំដើរទៅជាមួយគ្នា ទៅស្រុកភូមិយើងវិញ។» បាទប៉ុន្តែ នៅពេលដែលខ្ញុំចេញពីកំពតមួយទៅកំពតមួយទៅដល់កន្លែងមួយ ខ្ញុំគេចខ្លួនម៉ង គេចខ្លួនចូលព្រៃ។

ក៖ រត់ចេញ។

ខ៖ រត់ចេញម៉ង ចេញក្នុងព្រៃម៉ង បាទ។

ក៖ Wow.

ខ៖ ហើយពេលចេញហ្នឹង ប្រហែលជា៧ថ្ងៃ ៦ថ្ងៃ ៦ថ្ងៃបានដល់ជំរុំ ដល់ស្រុកថៃ។ ឆ្លងកាត់ច្រើនណាស់ ព្រៃភ្នំ ឆ្លងកាត់ច្រើនណាស់។ ហើយបានជួបប្រទះអ្នកដែលស្លាប់តាមផ្លូវ ដែលដើរជាន់មីន ច្រើនណាស់។ ហើយដើរទៅជួបវាយកសម្លាប់ចោល ឃើញឆ្អឹងតាមផ្លូវច្រើនណាស់។ ប៉ុន្តែខ្ញុំនៅប្រហឹលជាអ្នកស្រុកភូមិស៊ីវិលធម្មតា គ្នាអត់ដឹង ហើយខ្ញុំធ្លាប់ធ្វើទាហាន ខ្ញុំធ្លាប់ហាត់រៀនច្រើន មុនខ្ញុំចេញដើរពីកន្លែងមួយទៅកន្លែងមួយ ខ្ញុំនៅកន្លែងហ្នឹងយ៉ាងតិចទៅពីរម៉ោង សំងំមកនៅកន្លែងហ្នឹង។ បើមានពួកវាកងទៅមានសញ្ញាអីមួយ ស្រែកឬក៏អីមួយយើងបានឮដែរ។ បើថាអត់មានទេ យើងធ្វើដំណើរទៅតិចទៀត យើងឈប់នៅកន្លែងហ្នឹងទៀត។ ហ្នឹងហើយ បើសិនយើងអត់ដឹងត្រូវជួបវាបណ្តោយ។ បាទ ពេលទៅក៏វាមានខ្សែបី ខ្សែដើរវាមួយតូចទេ ខ្សែ rails គេដើរអញ្ចឹងណាស? អាហ្នឹងយើងអាចដើរកន្លងបាន យើងអាចដើរបាន។ ប៉ុន្តែខ្ញុំមុននិងឆ្លងហ្នឹង ខ្ញុំអង្គុយនៅកន្លែងហ្នឹងចាំមើលថា វាដើររបៀបម៉េច។ ពីរម៉ោងវាដើរម្តង ពីរម៉ោងវាដើរម្តង។ ហើយខ្ញុំដឹងអញ្ចឹងទៅ ខ្ញុំក្នុងពីរម៉ោងវាដើរចេញផុត ខ្ញុំក៏លេចចេញផុតភ្លាម។ ព្រោះពីទម្រាំតែវាដើរមកម្តងទៀតទៅវាពីរម៉ោង ហើយខ្ញុំបានទៅឆ្ងាយ។ ម្ល៉េះហើយទៅផ្លូវទីពីរគឺធំបន្តិច យើងអត់អាចកន្លងបានទេ។ ម្ល៉េះហើយទៅ គឺចាំកន្លែងហ្នឹង ឃើញវាដើរហើយវាដើរ ហើយវាចងមែកឈើពីក្រោយ ដើម្បីបោស ដើម្បីអាណាឆ្លងទៅឃើញគន្លងជើង (ស្នាមជើង)។ វាឆ្លាត! វាដើរ ពួកនោះអត់និយាយគ្នាម៉ង វាដើរស្ងាត់ល្អមែនទែន។ គ្រាន់តែឮសំឡេងកាំភ្លើង ដូចថា click click click click! អត់និយាយទៀត វាអត់និយាយគ្នាអីទេ។  ពេលណាខ្ញុំកន្លង លុតកន្លងដើរ ពេលណាខ្ញុំឆ្លងប្រហែលជាឃើញគន្លងជើងខ្ញុំ។ ម្ល៉េះហើយ ខ្ញុំដើរលើតែឈើ ជាន់លើឫសឈើ ផុតទៅ ផុតកន្លែងហ្នឹងទៀត។ ប៉ុន្តែដល់ទីបីធំម៉ង! ធំមែនទែន យើងមានទីបីធំ លោតក៏អត់ផុត កន្លែងហ្នឹងធ្វើអីក៏អត់ផុតម៉ង។ ពិបាកកន្លែងហ្នឹង អង្គុយកន្លែងហ្នឹងបានពីរម៉ោងជាងឃើញវាដើរមក ខ្ញុំសម្រេចចិត្តថា ប្រើល្បិចបន្តិច ដើម្បីឲ្យវាច្រឡំ ឲ្យវាភាន់ច្រឡំ មុននិងវាដឹងថាខ្ញុំប្រើល្បិចហ្នឹង ខ្ញុំទៅឆ្ងាយ។ ម្ល៉េះហើយ ខ្ញុំដើរថយក្រោយ ដើរថយក្រោយ។ ថយក្រោយ មុខយើងទៅនេះ យើងដើរទៅក្រោយ យល់អី?

ក៖ បាទ! យល់។

ខ៖ ដើរថយក្រោយ។ បើវាមើលឃើញគន្លងជើងទៅនោះវិញ យល់អី? បាទ ខ្ញុំបានដើរផុតពីកន្លែងហ្នឹង។ បើសិនណាជាខ្ញុំមិនធ្វើអញ្ចឹងវាឃើញគន្លងជើងខ្ញុំ ប្រហែលជាវាតាមទាន់។ ហើយនៅពេលឆ្លងកាត់ព្រៃភ្នំហ្នឹង អត់មានអីញ៉ាំ ញ៉ាំស្លឹកឈើ ស្លឹកឈើខ្ចី។ ញ៉ាំស្លឹកឈើខ្ចី

ឡើងដេកលើដើមឈើ ឡើងតាមវល្លិ៍ដើមឈើធំៗ ឡើងតាមវល្លិ៍ដេកលើឈើ យកក្រមាចង ហើយដេក។ ហើយវាមានដេកលក់ភ្លៀងមួយយប់ទល់ភ្លឺ មានដេកលក់អី។ ត្រជាក់ស្ងប់ហ្នឹង លើភ្នំហ្នឹង។ អត់មានលក់ទេ ចងដើម្បីខ្លាចយើងដេកលក់ទៅយើងធ្លាក់។ ប្រាំមួយ ជិតប្រាំមួយ យប់ដែរ បានឆ្លងដល់ស្រុកថៃ។ ដល់ស្រុកថៃទៅ ចូលចំការដល់ថៃ អត់អាហារយូរហើយ ឃើញពោតឃើញឪឡឹក អូ! ឃ្លានមែនទែនម៉ង។ អត់ញុំាអាហារច្រើនថ្ងៃ ហើយនៅស្គម ដូច ស្គមមែនទែនម៉ង ស្បែកឆ្អឹងពេលហ្នឹង។

ក៖ ហ្នឹង។

ខ៖ ចូលទៅលួចឪឡឹកគេញុំា លួចពោតគេញុំា ខ្ញុំឆ្អែតពេកពោះនិងប៉ោង ដេកលក់មិនដឹងខ្លួន ម៉ង។ (សើច) លក់និងចំការគេហ្នឹង! ហើយពោះនិងប៉ោង។ ហើយដល់ភ្ញាក់ឡើង «ចុំ! ដេក ច្រើនម៉ង! មកពីឆ្អែតពេក ខានញុំាយូរហើយ។» បាននិងខ្ញុំបានបង្ហាញខ្លួនទៅអ្នកចំការគេ។ កាលគេចាញមក គេឃើញខ្ញុំ យកកាំភ្លើងគេ កាំភ្លើងធម្មតា ស្រុកភូមិបានកាំភ្លើងទាហាន។ នាំ ខ្ញុំមកឡើងខ្ទមគេទៅ គេឲ្យបាយទឹកខ្ញុំទៀត។ ពេលហ្នឹងគេហៅពួកអាជ្ញាធរក្នុងថៃ គេមកយក ខ្ញុំទៅ។ បាទ ពេលគេយកខ្ញុំទៅ គេយកខ្ញុំទៅដាក់គុកងងឹត យកសួរចម្លើយហើយដាក់គុកងងឹ ត។ អត់មានភ្លើងចេញទៅ ងងឹតឆឹងម៉ង តូចមួយទេ។ ជិតបីខែដែរ គេសួរចម្លើយខ្ញុំ ខ្ញុំឆ្លើយ ប្រវត្តិថា ខ្ញុំធ្វើទាហានអីៗទាំងអស់ហ្នឹង។ ប្រាប់គេតាមត្រង់គេអត់ជឿខ្ញុំ គេថា «ចុះបើឯញធ្វើ ទាហាន ឬអីបានមិនគេចវេះតាំងពីឆ្នាំ៧៥? នៅជាមួយវាធ្វើអី?» គេសង្ស័យថា ខ្ញុំទៅស៊ើប ការណ៍អីឲ្យខ្មែរក្រហម គេសង្ស័យអញ្ចឹង! ម្ល៉េះហើយ ដាក់គុកខ្ញុំនៅក្នុងពីរបីខែហ្នឹង នៅក្នុងគុក ងងឹតហ្នឹង។ ពេលណាចេញក្រៅ មាន(ស្តាប់អត់បាន)តូចមួយ យើងបត់ជើងពេញ ពេញហើយ គេត្រូវការយើងទៅចាក់ចោល។ យល់អី? ដល់ពេញហើយយើងត្រូវការយកទៅចាក់ចោល។ រាល់ដងខ្ញុំចេញទៅយកទៅក្រៅហ្នឹង ពេលណាខ្ញុំឃើញថ្ងៃជះមុខខ្ញុំផុងខ្ញុំសន្លប់ដួលម៉ង។ ព្រោះមិនដែលឃើញពន្លឺ អត់ដែលឃើញពន្លឺទេ។ ដួលម៉ង គេលើកស្ទួយចាប់ខ្ញុំទាល់ប្រោះខ្លួន វិញទៅ។ បានជិតបីខែ ដល់ឡើងមកធ្វើអញ្ចឹងរាល់ដង។ ហើយខ្ញុំក៏បានទៅ បញ្ជូនខ្ញុំទៅកន្លែង គុកធំម៉ង។ ដូចកន្លែង prison ម៉ង។ Prison មនុស្សរាប់ ១០០០ នាក់ទៅដាក់ខ្ញុំនៅកន្លែងហ្នឹង ទៀត។ ហើយគេអ្នកដែលសួរចម្លើយខ្ញុំហ្នឹង ប្រហែលជាគេនឹងធ្វើសំណុំរឿងខ្ញុំទៅទូតអាមេរិ កាំងនៅបាងកក។ ព្រោះខ្ញុំប្រាប់គេថាខ្ញុំជាទាហានអាមេរិកាំងដែរ។ ហើយប្រហែលពេលហ្នឹង ហើយ បានជួបគុកនៅកន្លែងហ្នឹងបានប៉ុន្មានខែ ខ្ញុំចាំមិនបាន យូរគួរសមដែរ។ ឃើញទូតអា គាំងហ្នឹង មិនដឹងជាអាគាំង មិនដឹងជាបារាំង ឃើញជនជាតិស្បែកស ច្រមុះវែង ខ្ពស់ៗ មកសួរ

សុខទុក្ខខ្ញុំ សួរខ្ញុំ។ ហើយគិតថា កុំឲ្យភ័យគេនឹងជួយ។ បានគេចេញផុតទៅ បានប៉ុន្មានអាទិត្យហ្នឹង គេដក់ចេញខ្ញុំ ដក់ខ្ញុំចេញទៅនៅក្នុងជំរុំសុរិន្ទម៉ង។

ក៖ សុរិន្ទ។

ខ៖ បាទ។

ក៖ នៅថៃ?

ខ៖ បាទ។ ពេលនៅសុរិន្ទ ថៃហ្នឹងក៏— ខ្ញុំសរសេរសំបុត្របន្ថែមទៀត មកកន្លែងទូតអាគាំងនៅស្រុកបាងកកហ្នឹង ថាខ្ញុំចង់មកប្រទេសទីបី។ ពេលហ្នឹងហើយ គេក៏យល់ព្រមឲ្យខ្ញុំមកប្រទេសអាគាំងហ្នឹង ព្រោះគេដឹងថាខ្ញុំជាទាហានរបស់ជនជាតិអាគាំងដែរ មួយជំនាន់ហ្នឹង។ បាទ ហើយខ្ញុំចេញមកពីស្រុកថៃមក មកនៅហ្វីលីពីនបានបីខែ។ ចេញពីហ្វីលីពីនមក មកដល់រដ្ឋ Iowa.

ក៖ Iowa.

ខ៖ Mechanicsville រដ្ឋ Iowa នៅកន្លែងហ្នឹងបានឆ្នាំ ‘៨០— អូ! មកដល់ឆ្នាំ ‘៨០! មកដល់ឆ្នាំហ្នឹង ឆ្នាំ ‘៨០ ហ្នឹង ស្រុកអាគាំងហ្នឹង។ មុន Mt. St. Helens erupted, ហ្នឹងហើយ មុនហ្នឹងបាន— អូ! ក្រោយ! ក្រោយ ព្រោះខ្ញុំមក ‘៧៧ ខ្ញុំមក— អូ មិនទេ! មកខែ៧! ខែ៧ ខ្ញុំមកក្រោយពីរបីខែហ្នឹង។ ពេលហ្នឹងហើយ sponsor ខ្ញុំហ្នឹង គាត់ជាអ្នកសាងសងផ្ទះ a housebuilder, he’s a builder ។ គាត់ធ្វើ sponsor ខ្ញុំយកមកខ្ញុំ ឲ្យខ្ញុំចូលធ្វើការឲ្យគាត់ទៅម៉ង។

ក៖ បាទ។ នៅ Washington ឬក៏ Iowa?

ខ៖ នៅ Iowa State.

ក៖ Iowa. Okay, អ្នក sponsor នៅ Iowa ។

ខ៖ បាទ។ ពេលហ្នឹងធ្វើការ មួយម៉ោងបានបីដុល្លារ ម្ភៃប្រាំសេន ($3.25) ពេលហ្នឹង។ ធ្វើការកន្លែងហ្នឹង។ ពេលហ្នឹងអីវ៉ែអីវ៉ាន់ក៏ថោក ៨០សេន មួយគីឡូហ្នឹង ក្នុងជំនាន់ហ្នឹង មានថ្លៃអីវ៉ាន់ហ្នឹង ថោក។ ហើយទៅរៀន យប់ខ្ញុំទៅរៀន ថ្ងៃខ្ញុំធ្វើការដើម្បីចិញ្ចឹមគ្រួសារ។ មកដល់មុនដំបូងមានពិបាកច្រើន គិតច្រើន ព្រោះអីមកដល់ស្រុកគេហើយយើងអត់ចេះភាសាគេ។

កៈ ហ្នឹង។

ខៈ គិតច្រើនណាស់ អត់ចេះភាសាគេ។ គេនិយាយមកខ្ញុំមិនដឹងនិយាយអី។ យើងចង់និយាយ យើងមើលគេ អត់ដឹងភាសានិយាយ។ ចុះខ្ញុំអាចចិញ្ចឹមគ្រួសារបានរបៀបណា? មានពេលណាគេយកខ្ញុំទៅធ្វើការ បានថ្ងៃល្អ។ មើលទៅពិបាក ពេលហ្នឹងពិបាកមែនទែនម៉ង។ ពិបាករស់នៅ បញ្ហាគិតគូររឿងអនាគតគ្រួសារនិងឯង។ ប៉ុន្តែ ការព្យាយាមខ្ញុំដែលខំរៀនផង ធ្វើការផង រៀនតាមទូរទស្សន៍យើង uh, PBS រៀនក្មេងៗ រៀនតាមហ្នឹងឯង។ រៀនតាម រៀននិយាយជួនកាលដើរក្រៅ រៀននិយាយ រៀនប្រកបខ្លួនឯងហ្នឹងទាល់តែ— រៀនប្រដៅ ធ្វើការប្រដៅអីប៉ុណ្ណឹង ទាល់តែបានធ្វើការកន្លែងរោងចក្រមួយទៀត បានថ្លៃបន្តិច។ កន្លែងនេះគេហៅថា Nissin Corporation Company ធ្វើខាងកីឡាហ្នឹង។

កៈ កីឡា។

ខៈ កីឡា college សាលារៀនធ្វើអី ប្រហែលជាធ្លាប់ស្គាល់ឈ្មោះ Nissin, Nissin.

កៈ Nissin.

ខៈ ធ្វើបានកន្លែងហ្នឹង បានថ្លៃបន្តិចដែរដល់ឆ្នាំ ‘៨៩ ខ្ញុំចូលសញ្ជាតិជាអាមេរិកាំងបានមួយគ្រួសារ ចូលសញ្ជាតិជនជាតិអាមេរិកាំង។

កៈ បាទ។

ខៈ ពេលហ្នឹងហើយ ដល់ ‘៨៧ ខ្ញុំបានបងប្រុសខ្ញុំដែលស្លាប់ហ្នឹង ក៏នៅហ្នឹងកន្លែងនេះ។ ខ្ញុំមកលេងជាមួយគាត់។ មកលេងជាមួយគាត់ទៅ ឃើញស្រុកភូមិហ្នឹងសម្បូរព្រៃសម្បូរដើមឈើអីមិនវាលស្រែដូចនៅ Iowa ស្រុកវាលស្រែ។ ដើរទៅកន្លែងណាកន្លែងណា សុទ្ធតែគោក្របីជ្រូកស្អីពេញណាពេញអីហ្នឹងឯង។ បើឃើញព្រៃឃើញឈើ នឹកឃើញរឿងដើមខ្ញុំនឹកខ្ញុំនៅធំហ្នឹង ធំនៅក្នុងព្រៃ រស់ក្នុងព្រៃ ស្រឡាញ់ម៉ង។ ឃើញស្រឡាញ់ ក៏មកនៅកន្លែងហ្នឹងម៉ង។ បាទ ដល់មកកន្លែងហ្នឹងបានប៉ុន្មានឆ្នាំហ្នឹង មានបុរសពីរនាក់ ក្នុងឆ្នាំ ដើមឆ្នាំ ‘៩០ ១៩៩០ បុរសពីរនាក់រាងសង្ហា បានមកគោះទ្វារខ្ញុំ បើកទ្វារទៅនិយាយភាសាខ្មែរដែរ ខ្ញុំ ខ្ញុំក៏អញ្ជើញចូលក្នុង (សើច) ចូលក្នុងផ្ទះខ្ញុំ គេចាប់ផ្តើមបង្រៀនអំពីព្រះ ហើយខ្ញុំក៏ធ្វើជាសមាជិក។ (សើចទៀត)

កៈ សមាជិកក្នុងសាសនាចក្រយើង!

ខ៖ បាទៗ ហ្នឹងរហូតហ្នឹង ហើយបានការងារធ្វើបានគួរសមដែរ  បានថ្លៃគួរសមដែរ។ រហូតសព្វថ្ងៃហ្នឹង ខ្ញុំ retire បានបួនប្រាំឆ្នាំហើយ។ បាទ សព្វថ្ងៃហ្នឹងខ្ញុំទំនេរ។

ក៖ អរគុណច្រើនដែលបានចែកចាយបទពិសោធយ៉ាងក្បោះក្បាយទៀត! អរគុណ! ខ្ញុំមានសំណួរខ្លះៗ ចង់សួរដើម្បីរៀបរាប់បន្ថែម។ នៅក្នុងសម័យប៉ុលពត គេបានប្រើអ៊ំប្រុសដើម្បីធ្វើអ្វី?

ខ៖ ធ្វើស្រែ។

ក៖ ធ្វើស្រែចម្ការ?

ខ៖ ធ្វើស្រែចម្ការធម្មតា បាទ។

ក៖ Okay មួយទៀត ចង់សួរពេលចូលជំរុំនៅថៃមានអារម្មណ៍យ៉ាងម៉េចដែរ?

ខ៖ មានអារម្មណ៍នៅគិតដល់បងប្អូនស្រុកភូមិកំណើត។ គិតរបៀបថា homesick នៅគិត។ រស់នៅពិបាកមែន ប៉ុន្តែនឹកឃើញស្រុកកំណើតដែលធ្លាប់រស់នៅពីក្មេងរហូតដល់ធំ។ បាទ នឹកឃើញកន្លែងហ្នឹង។

ក៖ បាទ យល់ច្បាស់។ ចង់សួរមួយទៀតអំពីរឿងការរៀបការ បានរៀបការនៅណាដែរ? ខ្ញុំអត់ទាន់អំពីមួយហ្នឹង។

ខ៖ ប្រពន្ធដែលខ្ញុំរៀបការក្រមុំកំលោះជាមួយគ្នារៀបការនៅស្រុកខ្មែរហ្នឹងហើយ។

ក៖ នៅស្រុកខ្មែរ។ មុនប៉ុលពតមែន?

ខ៖ មុន។ កំពុងធ្វើទាហាន កំពុងធ្វើទាហាន។

ក៖ អូ! ហ្នឹង ពីព្រោះបានបែកពីគាត់នៅក្នុងសម័យប៉ុលពត។

ខ៖ បាតៗ កំពុងធ្វើទាហាននៅឡើយ មុនប៉ុលពតចូលហ្នឹង បាទ។

ក៖ អញ្ចឹងបានបែកពីគាត់។

ខ៖ ដល់ខ្ញុំមកស្រុកថៃ ខ្ញុំមកស្រុកថៃ ខ្ញុំមកតែខ្លួនឯងទេ ប្រពន្ធខ្ញុំមកតាមអត់ទាន់ព្រោះខ្ញុំគេចផុតតែខ្លួន ប្រពន្ធខ្ញុំកូនខ្ញុំទុកចោលនៅកន្លែងហ្នឹង។ មិនហ៊ានទៅប្រាប់ប្រពន្ធផង អត់មានពេលហ្នឹងផង! គេចខ្លួនផុត។

ក៖ ហ្នឹង។

ខ៖ ខ្មែរក្រហម គេជម្លៀសគាត់នៅខាងសៀមរាប ម្តុំកំពង់ថ្កូវហ្នឹង ជាមួយកូនខ្ញុំហ្នឹង។ គាត់ក៏បានប្តីជួយខ្មែរក្រហមទៀត

ក៖ Okay.

ខ៖ បានមួយខ្មែរក្រហម។ ខ្ញុំជួបគាត់លើកក្រោយថា «ហេតុអីបានយកប្តីខ្មែរក្រហម?» គាត់ថា «ដើម្បីជីវិត្ត!»

ក៖ ដើម្បីជីវិត្ត។

ខ៖ ហើយកូនយើងបានរស់ផង។ បាទ គាត់ប្រាប់អញ្ចឹង។

ក៖ ហើយពេលជួបជាមួយគាត់ម្តងទៀត នៅណា?

ខ៖ ជួបម្តងទៀត ជួបនៅជំរុំ។ គាត់ឡើងមកតាមក្រោយទៀត បន្ទាប់ពីយួនវាយចូលដេញខ្មែរក្រហមចេញ។

ក៖ Oh okay.

ខ៖ គាត់ក៏ឡើងមកតាមខ្ញុំមកតាមក្រោយទៀត មកតាមជំរុំហ្នឹងមក ជួបគ្នាកន្លែងហ្នឹង។ ពេលហ្នឹងហើយដែលគាត់និយាយប្រាប់ខ្ញុំ ខ្ញុំសួរគាត់។ ខ្ញុំក៏អាណិតគាត់ ប៉ុន្តែធ្វើដើម្បីជីវិតហើយដើម្បីកូនយើងបានរស់ដែរ។

ក៖ បាទ។

ខ៖ ព្រោះយើងធ្វើជាប្រពន្ធមេ គេដូចជាមេឃោធាដែរ។ អញ្ចឹងទៅគេបានចិញ្ចឹមកូនប្រពន្ធខ្ញុំបានល្អ កូនខ្ញុំបានល្អ។ ខ្ញុំក៏ឲ្យគាត់នៅជំរុំ ខ្ញុំអត់នៅជំរុំហ្នឹង ខ្ញុំនៅតាមព្រំប្រទល់ខ្ញុំធ្វើទាហានទៀត។ ខ្ញុំធ្វើទាហានទៀតដើម្បីចុះទៅវាយខ្មែរក្រហមទៀត ដេញមួយជំនាន់ទៀត ហើយ

ប្រពន្ធខ្ញុំនៅជំរុំ។ ហើយពេលខ្ញុំធ្វើទាហានសេរី វាយខ្មែរក្រហមវាយយួនហ្នឹង ប្រពន្ធខ្ញុំគេមានប្ដីទៀតព្រោះជំរុំហ្នឹង ជំរុំមានតែប្រុស! ច្រើនតែប្រុស ច្រើនពេក! អញ្ចឹងគេមានប្ដីទៀតទៅ។ បាទ មានប្ដីទៀត។

ក៖ Okay.

ខ៖ បាទ ហើយបែកបាក់គ្នាត្រឹមហ្នឹងទៀតមក ហើយខ្ញុំក៏ដឹងហ្នឹងថាគេមានប្ដី ខ្ញុំក៏សុំយកកូនគេហ្នឹងមកជាមួយ។ ដល់ខ្ញុំមកអាគាំងហ្នឹង ខ្ញុំយកកូនមកជាមួយ សុំកូនគេ។

ក៖ Okay.

ខ៖ គេឲ្យមក ព្រោះអី គាត់ខ្លាចខ្ញុំដែរមួយជំនាន់ខ្ញុំ។ បាទ គាត់ខ្លាចខ្ញុំធ្វើបាបគាត់ដែរ។ សូមរួចទៅខ្លួន។ បាទ ខ្ញុំបានកូនខ្ញុំមកនៅសព្វថ្ងៃ។

ក៖ ហើយដល់ពេលមកអាមេរិកវិញមានតែអាំប្រុសហើយកូនមែនទេ? ទាំងពីរទៅអាមេរិកជាមួយនឹងគ្នា?

ខ៖ បាទ មានកូនប្រុស ហើយពេលណាខ្ញុំបែកបាក់ជាមួយប្រពន្ធទីមួយខ្ញុំហើយ ខ្ញុំក៏បានប្រពន្ធលាវ ប្រពន្ធលាវទៀត។ ប្រពន្ធលាវនៅស្រុកថៃហ្នឹង បានកូនជាមួយគ្នា ពីរនាក់ដែរ។

ក៖ Okay.

ខ៖ ហើយខ្ញុំក៏យកគាត់មកស្រុកអាមេរិកហ្នឹងដែរ។ យកមកទៅ ដល់នៅ SIRHA បានប៉ុន្មានឆ្នាំគត់ គាត់ក៏មានបញ្ហាជាមួយគ្នាទៅក៏លែងលះគ្នាទៅ។ លែងលះគ្នាទៅក៏កូនចៅខ្ញុំ យកមកចិញ្ចឹមទាំងអស់ បានមកខ្ញុំទាំងអស់គត់។ អត់ឡើង court ឡើងតុលាការទៅ កូនពីរបីអ្នកបានមកជាមួយខ្ញុំទាំងអស់។

ក៖ Okay ទាំងអស់។

ខ៖ បាទ។

ក៖ ហ្នឹង។ ហើយគាត់មានឈ្មោះអ្វី? ប្រពន្ធទីពីរ?

ខ៖ Uh ឈ្មោះ ព្រំ យ៉ាន។ ប៉ុនការពិត ឈ្មោះគាត់ស្រុកថៃហ្នឹង ឈ្មោះពិតរបស់គាត់ មានឈ្មោះ និត ខ្យាន់វង់។

ក៖ Okay ហើយគាត់ជនជាតិថៃ?

ខ៖ គាត់ជនជាតិលាវ គាត់លាវប៉ុន្តែនៅស្រុកថៃ។

ក៖ លាវនៅស្រុកថៃ។ Okay យល់ច្បាស់។

ខ៖ បាទ។ គាត់រស់នៅសព្វថ្ងៃនៅ តាកូម៉ា ហ្នឹងដែរ។

ក៖ នៅ តាកូម៉ា ដែរ។

ខ៖ បាទ។ រស់នៅគាត់ ពេលណាបែកបាក់ជាមួយគាត់ហ្នឹងដែរហ្នឹង ខ្ញុំមានកូនពីរនាក់ដែរ។ បែកបាក់ជាមួយហ្នឹងគាត់បានឡើង ព្រោះគាត់ធ្វើខុសច្រើនពេក។ ម្ល៉េះហើយទៅឡើងតុលាការចាញ់ខ្ញុំ ខ្ញុំបានកូនមកខ្ញុំទាំងអស់ដែរ ខ្ញុំប្រុសចិញ្ចឹមកូនរហូត។ (សើច) បាទ។

ក៖ ហើយកូនទាំងអស់មានឈ្មោះអ្វី? អាចរៀបរាប់សម្រាប់ខ្ញុំបានទេ?

ខ៖ Okay កូនខ្ញុំនៅ កូនជាមួយប្រពន្ធទីមួយឈ្មោះ អាន សូម៉ាឡាយ។

ក៖ អាន សូម៉ាឡាយ។

ខ៖ បាទ។ ហើយកូនជាមួយលាវហ្នឹងឈ្មោះ អាន ចន្ទទេវី។

ក៖ អាន ចន្ទទេវី។

ខ៖ បាទ។ ប្អូនស្រី កូនស្រីមួយទៀតឈ្មោះ អាន មីនា។

ក៖ អាន មីនា។

ខ៖ បាទ។ អាន មីនា គាត់នៅ Iowa ដែរ។

ក៖ នៅសព្វថ្ងៃគាត់នៅ Iowa.

ខ៖ បាទ នៅ Iowa.

ក៖ ហើយកូនទីមួយ កូនប្រុសឬក៏កូនស្រី? សុំទោសខ្ញុំអត់ឮ។

ខ៖ ប្រុស។ កូនប្រុស បាទ។

ក៖ ប្រុស Okay ហើយចាំឆ្នាំកំណើតគាត់ទេ?

ខ៖ អូ! ចាំមិនបាន។ (សើច) អាយុគាត់ ៥០ ហើយ ៥០ជាងហើយ។

ក៖ ៥០ជាងហើយ។ Okay គាត់មុនប៉ុលពត គាត់កើតមុនប៉ុលពត?

ខ៖ កើតនៅឆ្នាំ '៧៥ ប៉ុលពតចូលឆ្នាំហ្នឹង។

ក៖ '៧៥។ Oh okay គាត់កើតនៅឆ្នាំប៉ុលពតចូល។

ខ៖ បាទ។

ក៖ Okay កូនទីពីរជាមួយប្រពន្ធទី២? គាត់ប្រុសឬស្រី?

ខ៖ ស្រី។ ចន្ទទេវី កើតឆ្នាំ '៧៩។

ក៖ Okay ទីបី ស្រីដែរ?

ខ៖ ទីបី ស្រីដែរ។ កើតនៅ Iowa State.

ក៖ ហ្នឹង Okay ល្អ។ ហើយមានតែបីហ្នឹង?

ខ៖ បាទ មានតែបីហ្នឹង។ ប៉ុនដល់ពេលបែកបាក់ពីគាត់ទៅ ខ្ញុំក៏បានមកនៅរដ្ឋ Washington ហ្នឹងឯង។ នៅ Washington ហ្នឹង ហើយខ្ញុំយកកូនមកទាំងអស់ ព្រោះខ្ញុំបានឈ្នះលើកឡើងតុលាការ ឈ្នះយកកូនមកទាំងអស់ហ្នឹង។ ចិញ្ចឹមថែរក្សាហ្នឹងនៅ apartment មួយ ចិញ្ចឹមកូនហ្នឹងឯង។ បាទ ហើយដល់ ដល់មកនៅហ្នឹងទៅខ្ញុំមានគ្រួសារមួយទៀត។ មានគ្រួសារមួយទៀត បានកូនពីរបីនាក់ បីនាក់ទៀត។

ក៖ បីនាក់ទៀត។

ខ៖ បាទ។

កៈ Okay ហើយឈ្មោះគេ?

ខៈ ឈ្មោះគាត់ ពៅ រេត ប៉ុន្តែឈ្មោះពិតប្រាកដរបស់គេឈ្មោះ ពៅ សារ៉ូនី។

កៈ ពៅ សារ៉ូនី។

ខៈ បាទ។

កៈ ហើយកូនទីពីរ?

ខៈ ណាគេ?

កៈ ដូចអ៊ំប្រុសបាននិយាយថា មានគ្រួសារមួយទៀតមែន?

ខៈ បាទ ហ្នឹងហើយឈ្មោះ សារ៉ូនី ហ្នឹងហើយ។

កៈ សារ៉ូនី អូ! គាត់ជាប្រពន្ធ?

ខៈ ប្រពន្ធទីបី។

កៈ ប្រពន្ធទីបី គាត់ឈ្មោះ— ?

ខៈ សារ៉ូនី។

កៈ អូ! Okay ខ្ញុំយល់ច្បាស់សុំទោស ខ្ញុំយល់ខុស។

ខៈ បាទ សារ៉ូនី ហើយបានកូនបីនាក់។

កៈ កូនបីនាក់ ហើយគេឈ្មោះអ្វី?

ខៈ បងគេឈ្មោះ អេព្រលិន! អាន អេព្រលិន។ (Apilynn) បាទ វាកើតខែ April ខ្ញុំដាក់ អេព្រលិន។ ហើយ មីនា កើតខែមីនា ខ្ញុំដាក់ មីនា។ (សើច)

កៈ (សើច) ហើយទីបី?

ខៈ Uh កូនបន្ទាប់ពី អេព្រលិន ឈ្មោះ អ៊ីលីសាបែត។ (Elizabeth) អ៊ីលីសាបែត អាន។ បន្ទាប់ពី អេព្រលិន។

កៈ Oh អេព្រលិន។ ហើយទីពីរឬក៏ទីបី?

ខៈ គាត់ទីពីរ អ៊ីលីសាបែត ទីពីរ។

កៈ Okay ហើយទីបី?

ខៈ ទីបី ចូសែព។ (Joseph)

កៈ ចូសែព។

ខៈ ចូសែព អាន។

កៈ ចូសែព អាន។

ខៈ បាទ ខ្ញុំដាក់ឈ្មោះ Joseph after our prophet. (សើច)

កៈ ក្រោយពីជួបជាមួយនិងព្រះវិហារយើង។

ខៈ Yeah. I like—I want his name after the prophet. (សើចទៀត)

កៈ ល្អ Okay ខ្ញុំសូមរៀបរាប់ម្តងទៀតដើម្បីបញ្ជាក់ថាខ្ញុំយល់ត្រឹមត្រូវ។ មានប្រពន្ធចំនួនបី។

ខៈ បាទ បី។

កៈ ទីមួយមានកូនមួយនាក់ ទីពីរមានកូនពីរនាក់ ទីបីមានកូនបីនាក់។ មួយ ពីរ បី okay!

ខៈ បាទៗ

កៈ ល្អ Okay បានហើយ។

ខៈ ពេលហ្នឹងក៏បាន គាត់ធ្វើខុសច្រើននិងច្បាប់ខាង ធ្វើខាងផ្លូវច្បាប់ច្រើនណាស់ហ្នឹង។ ខុសច្រើនក៏បានបែកបាក់គ្នាទៅ។

កៈ ប្រពន្ធទីបី?

ខ៖ បាទ បែកបាក់ គាត់ខុសច្រើនទៅគាត់មានហ៊ាននៅស្រុកអាមេរិច គាត់ទៅស្រុកខ្មែរ។ គាត់នៅជួបគុក ព្រោះថា គាត់ទៅស្រុកខ្មែរ គាត់នៅស្រុកខ្មែរសព្វថ្ងៃហ្នឹង គាត់អត់ហ៊ានមកទេ។ គាត់ជាសញ្ជាតិអាគាំងដែរ។

ក៖ Oh okay.

ខ៖ ម្លេះហើយ ឡើង court ក៏កូនខ្ញុំបានមកខ្ញុំទៀតហ្នឹង! ទាំងអស់ហ្នឹង ពីរបីនាក់ហ្នឹង! (សើច) បាទទាំងអស់ហ្នឹង។ បាទ គាត់នៅស្រុកខ្មែរសព្វថ្ងៃហ្នឹង។

ក៖ Okay នៅស្រុកខ្មែរហ្នឹងនៅសព្វថ្ងៃ។

ខ៖ បាទ នៅភ្នំពេញ បាទ។

ក៖ Okay ចង់សួរ ពីព្រោះអ៊ំប្រុសបានរៀបរាប់ច្រើនមែនទែន អំពីបទពិសោធន៍ទាំងឡាយតាំងពីតូចរហូតដល់បច្ចុប្បន្ននេះ។ ចង់សួរថាពេលវេលាដែលពិបាកជាងគេ គឺពេលណាដែរ?

ខ៖ ស្តាប់មិនបាន ថាម៉េច?

ក៖ អូ ចង់សួរថា បើគិតទៅតាំងពីដើម តាំងពីកើតរហូតដល់បច្ចុប្បន្ននេះ គិតថាបទពិសោធន៍ពិបាកជាងគេគឺជាអ្វី?

ខ៖ ពិបាកជាងគេ គឺការរស់នៅនិងសេរីភាព ហើយនិងអ្វីៗដែលយើងចង់ធ្វើនៅស្រុកខ្មែរវាពិបាកជាងគេ។

ក៖ ពិបាកជាងគេនៅស្រុកខ្មែរ?

ខ៖ បាទៗ

ក៖ ចុះ ខ្ញុំចាំថាអ៊ំប្រុសបាននិយាយថា នៅក្នុងសម័យប៉ុលពត អ៊ំចេះរៀនតាមគេបានមើលគេរៀនតាមគេ។ ចង់សួរថា នៅក្នុងបទពិសោធន៍ពិបាកទាំងហ្នឹង អ៊ំបានរៀនអ្វីខ្លះដើម្បីជួយអ៊ំប្រុស?

ខ៖ Uh រៀនអំពីអ្វីៗដែលគេធ្វើហ្នឹង យើងយកមកពិចារណា ហើយយើងចេះដោះស្រាយខ្លួនយើងយកហ្នឹងមកប្រើដើម្បីជីវិត្តរបស់យើង។

កៈ ដើម្បីជីវិត្ត។

ខៈ បាទ ដើម្បីជីវិត្តយើង ដើម្បីបានរស់នៅរៀនសូត្របៀបហ្នឹង។ យើងមិនមែនធ្វើខ្មែរយើងថា អត់មានដំឡូងមូលសូត្រសារទេ មែនទេ។ ប៉ុន្តែយើង ការធ្វើ acting, yeah like that. You know, but you study and look at them and—study about them, yeah.

កៈ ហើយ ត្រឡប់ទៅបទពិសោធន៍ល្អជាងគេវិញ។ ចង់សួរថា បទពិសោធន៍ល្អជាងគេនៅក្នុងជីវិត្តរបស់អ៊ំប្រុសគឺជាអ្វី?

ខៈ បទពិសោធន៍ល្អបំផុតជាងគេ នៅពេលដែលខ្ញុំក្លាយខ្លួនជាសមាជិកព្រះវិហារបរិសុទ្ធនៃថ្ងៃចុងក្រោយ។ ពេលហ្នឹងហើយខ្ញុំបានរៀនសូត្រអំពីព្រះគម្ពីរបានច្រើន ហើយនិងដឹងយល់ច្រើនក្នុងការគ្រប់គ្រងគ្រួសារ ក្នុងការរកសុភមង្គលជូនគ្រួសារ ខ្ញុំមានសេចក្តីសុខក្នុងអារម្មណ៍ខាងផ្លូវការអីទាំងអស់ហ្នឹង។ ហ្នឹងហើយខ្ញុំមានវាសនាហើយនិងសំណាងល្អណាស់ដែលបានមកស្រុកអាមេរិក ហើយបានជួបនិងរៀនហើយបានស្គាល់អំពីព្រះ។ ខ្ញុំនៅតែគិតឃើញរាល់តែថ្ងៃរាល់តែដងឃើញថា ខ្ញុំមកស្រុកអាមេរិកនេះ ខ្ញុំមែនមកដោយចៃដន្យទេ។ ខ្ញុំមែនមកដោយចៃដន្យអ្វីទេ គេថាមកដោយមកពីព្រះឲ្យនាំខ្ញុំមកកន្លែងដូចខ្មែរគេថា promised land ហ្នឹងហើយ។

កៈ ត្រូវ!

ខៈ មកដូចថា it’s not an accident, on purpose. God’s purpose brought me here. ហើយពេលណាខ្ញុំមករៀនអំពីព្រះអំពីសាសនាយើងទាំងអស់ ជាពិសេសសមាជិកយើងនៅក្នុងព្រះវិហាររបស់យើងហ្នឹង។ ខ្ញុំរៀនសូត្របានច្រើន ពេលណាខ្ញុំឃើញ រៀនសូត្រដឹងអំពីកាលដែលសមាជិកយើងភៀសខ្លួនចេញពី New York ទៅ Utah, they ហៅថា pioneer ហ្នឹងហើយ។ ខ្ញុំគិតខ្លួនខ្ញុំជា pioneer មួយដែរ ព្រោះខ្ញុំចេញពីស្រុកខ្មែរមុនអញ្ចឹងដែរ។ ខ្ញុំគិតមួយអញ្ចឹងថាខ្ញុំខ្មែរ pioneer ខ្មែរដែរ។ ហើយគិតឃើញមួយទៀតរៀនអំពី Lehi’s family that fled from the Jerusalem.

កៈ ហ្នឹង!

ខៈ Pretty much the same thing, like that, like my life. Yeah, I said, “Oh! I am a pioneer!” (សើច) Yeah, ខ្ញុំបានរៀនច្រើនដឹងច្រើន ហើយខ្ញុំយកមកគិត ហើយនិងខ្ញុំគិតថាខ្ញុំមានសំណាងល្អ ជាពិសេសបានមកដល់ព្រះ ព្រះបានឲ្យពរជ័យខ្ញុំ។ បាទ ហើយបានមានសុភមង្គលរហូត។ ហើយបានប្រពន្ធដ៏ល្អទៀត ល្អទាំងចិត្តល្អទាំងរូបរាងកាយ ល្អទាំងអស់ទៀត

ប្រពន្ធក្រោយហ្នឹង។ ការពិត ប្រពន្ធខ្ញុំគាត់ជាសមាជិកហ្នឹងដែរពីមុនហ្នឹង ប៉ុន្តែប្តីគាត់ស្លាប់។ ប្តីគាត់កើតស្ទះបេះដូង heart attack ពេលណាគាត់ heart attack ទៅគាត់ស្ទះបេះដូង គាត់ stroke ប៉ុន្មាន— uh, ដប់ឆ្នាំជាងអី? (គាត់សួរប្រពន្ធ) ដប់ឆ្នាំគាត់មើលថែរក្សាប្តីគាត់ដប់ឆ្នាំនៅលើគ្រែហ្នឹង គេដាក់ទុយោបញ្ចុះអាហារនៅកន្លែងហ្នឹង អត់មានងើបបានក្រោកបានអីទេ។ បើកឃើញតែភ្នែកហ្នឹង បានដប់ឆ្នាំបានកាត់ស្លាប់។ ហើយខ្ញុំជួបគាត់ ជួបនៅព្រះវិហារហ្នឹងដែរ ខ្ញុំទៅព្រះវិហារជួបគាត់ហ្នឹងក៏បានទាក់ទងគ្នា មើលចិត្តថ្លើមគ្នាទៅវិញទៅមក ក៏បានយល់ចិត្តទាំងអស់គ្នាថា យើងនិងយកធ្វើជាអនាគតជាមួយគ្នាហ្នឹង។ បាទ បានជួបមួយគាត់ហ្នឹង ហើយគាត់មានកូនបីបួននាក់ដែរទាំងអស់ហ្នឹង បាទ។

ក៖ ហើយគាត់ឈ្មោះអ្វី សុំទោសអត់ស្គាល់គ្នា?

គ៖ ខ្ញុំ អាគាំងគេហៅ ឡានេ។

ក៖ ឡានេ?

ក៖ ហ្នឹងឈ្មោះគាត់ មកដល់កន្លែងគាត់ដាក់ ពេលណាគាត់ចូលសញ្ជាតិ គាត់ដាក់ឈ្មោះ ឡានេ។ ប៉ុន្តែឈ្មោះខ្មែររបស់គាត់ពីមុនឈ្មោះ ឈុនឡេង។

ក៖ ឈុនឡេង។

ក៖ ឈុនឡេង បាទ។

ក៖ Okay ហើយគាត់ជាប្រពន្ធទីបួន?

ខ៖ ទីបួន បាទ។

ក៖ Okay មានកូនជាមួយគាត់ទេ?

ខ៖ អត់មានទេ។

ក៖ អត់មានអី?

ខ៖ អត់មានទេ។

ក៖ Okay គ្រាន់តែរៀបការជាមួយគ្នា។ ចុះបានរៀបការជាមួយនឹងគាត់នៅឆ្នាំណាដែរ?

ខ៖ ឆ្នាំ ២០០០។

ក៖ ២០០០ គត់។

ខ៖ បាទ ឆ្នាំ ២០០០។

ក៖ Okay អញ្ចឹងនៅជាមួយនឹងគ្នាម្ភៃពីរឆ្នាំ! អបអរសាទរ!

ខ៖ បាទ! (សើច)

ក៖ ល្អ ហើយបានជួបជាមួយគ្នានៅ តាកូម៉ា មែន?

ខ៖ បាទ នៅកន្លែងតាកូម៉ា នៅកន្លែង church យើងម៉ង! (សើច)

ក៖ ល្អ ហើយចូលសាសនាចក្រ ព្រះវិហារយើងនៅឆ្នាំណាដែរ?

ខ៖ ចូលជាសមាជិកហ្នឹងហើយ?

ក៖ ហ្នឹង!

ខ៖ ខ្ញុំចាំមិនបាន ប្រហែល early '90s.

ក៖ Early '90s?

ខ៖ ហ្នឹងហើយ ខ្ទង់កៅសិប ដើមឆ្នាំ '៩០ ហ្នឹងហើយ។ ប្រហែលជា ៩១ ក៏យូរខ្ទង់ហ្នឹងហើយ។

ក៖ ហើយចាំឈ្មោះអែលឌើរដែលបានធ្វើបុណ្យជ្រមុជទឹកឲ្យ ឬក៏អត់ចាំឈ្មោះទេ?

ខ៖ Uh ឈ្មោះអែលឌើរដែលបានបង្រៀនខ្ញុំ ជ្រមុជទឹកខ្ញុំឈ្មោះ Elder David Landward.

ក៖ Landward?

ខ៖ គាត់នៅ Utah.

ក៖ គាត់នៅ Utah.

ខ៖ ហើយ companion របស់គាត់ឈ្មោះ កែវ តាព។

កៈ កែវ តាភា។ អូ គាត់ជនជាតិខ្មែរ?

ខៈ ជនជាតិលាវ។

កៈ មែន!

ខៈ លាវ បាទ។ ប៉ុន្តែខ្ញុំ search រកគាត់ មិនដែលឃើញឥឡូវហ្នឹង។ រកគាត់មិនដែលឃើញ គាត់ល្អ! ចេះហូរហែ ចេះនិយាយ គាត់ baptize ខ្មែរច្រើន បានប្រហែរជា ២០០-៣០០ នាក់ហ្នឹង គាត់ធ្វើបាន។ ច្រើន គាត់ល្បីជាងគេម៉ង។

កៈ ច្រើន! (សើច) ល្បីជាងគេ។

ខៈ បាទ។

កៈ Okay ប្រហែលជាខ្ញុំមានសំណួរតិចតួចចង់សួរទៅ ដូចសំណួរថា ធ្លាប់មានល្បែងឬក៏ game មួយដែលអ៊ំចូលចិត្តលេងជាមួយក្រុមគ្រួសារ ពេលនៅក្មេងឬក៏នៅបច្ចុប្បន្ននេះ? នេះជាសំណួរតិចតួច ខ្ញុំគ្រាន់តែចង់បន្ថែម។

ខៈ Uh អត់មានអីផង។ ធ្វើកិច្ចការនៅក្នុងផ្ទះជាមួយគ្នា ជួយគ្នានៅក្នុងកិច្ចការក្នុងផ្ទះ។ ហើយខ្ញុំចេះលេងភ្លេងតិចតួចដែរ ចេះកូតទ្រដែរ ទ្រហ្នឹង។ (គាត់ចង្អុល)

កៈ អូមែន? ចេះលេងទ្រ!

ខៈ បាទ! (សើច)

កៈ អូ ខ្ញុំមានទ្រនៅផ្ទះខ្ញុំ ប៉ុន្តែខ្ញុំអត់ចេះលេង! (សើច) ចុះអ៊ំចេះលេងឧបករណ៍អីទៀតទេ?

ខៈ មានតែទ្រហើយនិងស្គរហ្នឹង។

កៈ ស្គរទៀត។

ខៈ រៀនអី—

កៈ ចេះច្រៀងទេ?

ខ៖ ពីដើមមិញខ្ញុំពីរោះ ច្រៀងពីរោះពីដើម! (គេសើច) បាទ ប៉ុន្តែឥឡូវនេះអត់ទេ បំពង់កបែកអស់ហើយ។

ក៖ ចូលចិត្តច្រៀងអី— ?

គ៖ បែកសំឡេង? (គេសើច)

ខ៖ ខ្ញុំច្រៀង អត់ទេ! ខ្ញុំចូលចិត្តឃ្វាលគោ ច្រៀងបទល្ខោនបាសាក់ ល្ខោនបាសាក់ដូចសុរិន្ទ ហ្នឹងហើយ! បាទច្រៀង ខ្ញុំចូលចិត្តច្រៀងហ្នឹង។ ខ្ញុំឡើងដើមឈើ ឡើងបេះផ្លែឈើច្រៀង។ មានន័យថា នៅវាលស្រែឡើងបេះផ្លែឈើច្រៀង! វាពីរោះចាស់ៗចូលចិត្តស្តាប់។ បាទល្ខោន បាសាក់ហ្នឹង ជំនាន់ហ្នឹង។

ក៖ ហ្នឹង។ ហើយអ៊ំធ្លាប់ចូលចិត្តតារាដូចជា ស៊ីន សាមុត ឬក៏ មានអ្នកណាដែលអ៊ំចូលចិត្ត ស្តាប់គេច្រៀង?

ខ៖ ចូលចិត្តអីគេ? សុំម្តងទៀត?

ក៖ Uh, ចង់សួរថា មានតារា ឬក៏មានម្នាក់មួយចូលចិត្តស្តាប់— ?

ខ៖ Oh! ចូលចិត្ត ចូលចិត្តជាងគេមានតែពីរ មានតែពីរទេ។ រស់ សេរីសុទ្ធា និង ស៊ីន ស៊ីសាមុត ហ្នឹងគាត់នៅជំនាន់ខ្ញុំដែរ។ គាត់នៅជំនាន់ខ្ញុំដែរមុនជំនាន់ដែល— បើចាស់ជាងខ្ញុំតិចដែរ ប៉ុន្តែ គាត់ ពេលហ្នឹងគាត់ច្រៀង ពេលណាខ្ញុំកំពុងធ្វើទាហានដែរ។

ក៖ បាទ។

ខ៖ ហើយសំឡេងបំពេពីរោះជាងគេ បំពេពីរោះជាងគេ សូ សាវឿន។

ក៖ សូ សាវឿន។

ខ៖ បាទ សូ សាវឿន។ ឥឡូវគាត់នៅស្រុកបារាំងឥឡូវហ្នឹង។

ក៖ បាទ ល្អ។ ហើយខ្ញុំចាំពេលចូល Iowa ពេលមកអាមេរិកចូល Iowa អ៊ំប្រុសបាននិយាយថា អ៊ំបានរៀនសូត្រ។ អ៊ំបានរៀននៅខាងណាដែរ? ហើយបទពិសោធន៍ហ្នឹងវាពិបាកឬក៏— ?

ខ៖ បាទៗ រៀនយប់ រៀនរហូតដល់ទទួលខ្ញុំបាន LE— uh, ដល់ uh, ED—

ក៖ GED?

ខ៖ GED បាទ!

ក៖ ហើយរៀនភាសាអង់គ្លេសមែន?

ខ៖ បាទ! រៀនភាសាអង់គ្លេស។

ក៖ ចុំ!

ខ៖ Yeah រៀនយប់ហ្នឹងហើយ រៀនយប់ប៉ុន្មានឆ្នាំ ខំរៀនទាំងយប់ទាំងថ្ងៃ។ ធ្វើការយប់ឡើងរៀន ហើយថ្ងៃសំរាក ថ្ងៃអាទិត្យថ្ងៃសៅរ៍ខំប្រឹងមើលទូរទស្សន៍ PBS. (សើច)

ក៖ PBS ដូចកូនក្មេង។

ខ៖ ហ្នឹងហើយ។

ក៖ Okay ល្អ។ ប្រហែលជាខ្ញុំអស់សំណួរ។ អរគុណច្រើនសម្រាប់ការសម្ភាសយ៉ាងក្បោះក្បាយ!

ខ៖ បាទ! ហើយខ្ញុំមកនេះ មកហ្នឹងមកធ្វើការ បានធ្វើការនៅកន្លែង តាកូម៉ា ហ្នឹងបានរោងចក្រចុងក្រោយគេបង្អស់ហ្នឹង ខ្ញុំក៏ធ្វើនៅកន្លែងឈ្មោះ General Plastic Company.

ក៖ Oh okay!

ខ៖ ខ្ញុំនៅកន្លែងហ្នឹងធ្វើ មុនដំបូងធ្វើ production worker ធម្មតា។ ធ្វើធម្មតា យូរៗទៅថៅកែហ្នឹង គាត់ពេញចិត្តខ្ញុំ ខ្ញុំធ្វើការល្អ។ ហើយគាត់មើលថា ខ្ញុំមានដូចខួរក្បាលល្អឆ្លាតឈ្លាសវៃ។ គាត់ក៏សុំឲ្យខ្ញុំទៅរៀន គាត់បង់ថ្លៃសាលារៀនឲ្យ។ គាត់ឲ្យទៅរៀនធ្វើជា machinist.

ក៖ មែន!

ខ៖ បាទ ខ្ញុំរៀនបាន machinist គេបង់ថ្លៃសាលាឲ្យទៅ ខ្ញុំក៏មកចូលធ្វើការកន្លែងគាត់ហ្នឹងទៅខ្ញុំ become a machinist, yeah.

ក៖ Oh ល្អ!

ខ៖ I make parts for Boeing, Lockheed Martin, make the parts for drones too. ខ្ញុំធ្វើ part ច្រើនសម្រាប់ government, វា secret.

ក៖ It was secret, whoa!

ខ៖ Every time you make a part, done, and the blueprint— you got to shred it out, throw it away. You can't leave it around because it was so secret. If someone needs that blueprint, they can go out and print it again. So yeah, it was very secret.

ក៖ Wow!

ខ៖ And I have a pin from NASA because I make floor for them. After their explode one time, last time, they— they let us make a floor out of foam, high density foam. Yeah, made a floor for them. Then they came to visit us, they gave us each machinists a pin, so I have—

ក៖ That's amazing!

ខ៖ And then, uh— every time I wear it people ask, "How did you get that pin?" and I say, "Well, it's a long story." And then I'll tell them, and they'll say, "Wow!" But yeah, I don't know. I'm lucky!

ក៖ That's amazing! Okay ហើយសំណួរជាចុងក្រោយដែលខ្ញុំចង់សួរគឺពាក់ព័ន្ធទៅនិងការទុកពាក្យសម្ដីរបស់អ៊ំប្រុស ទៅកាន់ជំនាន់ក្រោយ។ ចង់សួរថាអ៊ំមានពាក្យពេចន៍អីចង់ផ្ដាំផ្ញើឲ្យជំនាន់ក្រោយ ដូចជាកូនចៅឬក៏មនុស្សដែលនឹងស្ដាប់ការសម្ភាសន៍ពេលក្រោយ?

ខ៖ បាទ។ ខ្ញុំគ្រាន់តែប្រាប់ឲ្យដឹងថាកាលដើមឡើយ នៅពេលដែលខ្ញុំមិនទាន់ស្គាល់សាសនាចក្រយើង ខ្ញុំមិននឹកស្មានថាជីវិតខ្ញុំបានល្អប្រសើរដូចសព្វថ្ងៃនេះទេ។ ខ្ញុំចង់ឲ្យបងប្អូនកូនក្មួយមិត្តភក្ដិណាមួយឬក៏អ្នកដទៃណាមួយដែលបានឮសំឡេងខ្ញុំ សូមឲ្យយកចិត្តទុកដាក់ស្ដាប់ហើយនិងយល់ថាមានតែផ្លូវមួយទេ ដើម្បីរកអនាគតរបស់យើង ហើយដើម្បីមានសុភមង្គលនៅក្នុងក្រុមគ្រួសាររបស់យើង គឺយើងតាំងចិត្តដើរតាមព្រះ ព្រះយេស៊ូវរបស់យើងហ្នឹង។ ហើយពេលណាឃើញអ្នកបេសកកម្មខាងសាសនាដើរតាមផ្លូវ សូមអញ្ជើញឲ្យបងប្អូនហៅរកផង ហើយអនុញ្ញាតអោយគេចូលក្នុងផ្ទះដើម្បីគេបង្រៀនដំណឹងល្អឲ្យយើងបានដឹង។ ហើយយើងនឹងបានល្អ ហើយយើងនឹងមានជោគជ័យនៅពេលហ្នឹងដែរ។ ហើយយើងនឹងមាន

វាសនាល្អ ហើយនិងបានត្រឡប់ទៅរកព្រះវិញ នៅពេលណាយើងចែកឋានហ្នឹងទៅ។ តែប៉ុណ្ណឹងឯង។

ក៖ Okay អរគុណច្រើនអ៊ំប្រុសដែលបានរៀបរាប់យ៉ាងក្បោះក្បាយ ដែលបានចែកចាយបទពិសោធន៍ទាំងឡាយ។ ខ្ញុំពិតជាសប្បាយចិត្ត អ៊ំបានលើកទឹកចិត្តខ្ញុំដែរ។

ខ៖ បាទ។

ក៖ អញ្ចឹងសម្រាប់ពួកយើង ពេលក្រោយ អ្វីដែលយើងនឹងធ្វើក្រោយពីយើងចប់ការថតសំឡេងនៃការសម្ភាសន៍មួយនេះ យើងនឹងឲ្យ copy មួយទៅអ៊ំប្រុស ដើម្បីអ៊ំប្រុសអាចស្តាប់។ បើមានអ្វីមួយចង់ថែមឬក៏ចង់ដក អាចប្រាប់ឲ្យពួកយើងបាន។ ហើយក្រោយមកយើងនឹងដាក់មួយហ្នឹងទៅលើ website របស់ពួកយើង។

ខ៖ បាទ។

ក៖ ហើយចាំខ្ញុំផ្ញើ link website ឲ្យអ៊ំប្រុសពេលក្រោយ ដើម្បីអ៊ំប្រុសអាចស្តាប់បាន។ អញ្ចឹងជាចុងក្រោយ អរគុណច្រើនអំប្រុស!

ខ៖ បាទ អរគុណដែលបានអញ្ជើញមកផ្ទះខ្ញុំ៕